# សេចក្តីប្រកាសព័ត៌មាន

## យើងត្រូវការច្បាប់សិទ្ធិទទួលព័ត៌មាន

បច្ចុប្បន្ននេះយុវជន ក៏ដូចជាប្រជាពលរដ្ឋកម្ពុជាជាច្រើន មានតម្រូវការយ៉ាងខ្លាំងអំពីព័ត៌មានសាធារណៈ ជាពិសេសព័ត៌មានពាក់ព័ន្ធនឹងការអប់រំ ការងារ កិច្ចការសង្គម សេដ្ឋកិច្ចជាតិ នយោបាយ វប្បធម៌ និងផែនការអភិវឌ្ឍន៍នានា។ ចំណែកឯបញ្ហាវិវាទដីធ្លី និងបញ្ហានៅមូលដ្ឋានមួយចំនួនទៀតសុទ្ធតែទាក់ទងនឹងសិទ្ធិទទួលព័ត៌មាន និងការបើកចំហព័ត៌មាននេះ។

ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការចាប់ផ្តើមដំណើរការតាក់តែងសេចក្តីព្រាងច្បាប់ស្តីពី សិទ្ធិទទួលព័ត៌មាន ទទួលបានការកោតសរសើរគួរឲ្យកត់សម្គាល់ ហើយក្រុមការងារអង្គការសង្គមស៊ីវិលបានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងទាំងនេះ ជាពិសេសក្រោមការសហការដឹកនាំ ដោយក្រសួងព័ត៌មាន និងអង្គការយូណេស្កូ ដែលបានបង្កបរិយាកាសល្អប្រសើរដល់អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា ក្នុងដំណើរការពិគ្រោះយោបល់ ។ កម្ពុជាបានសម្រេចនូវសេចក្តីព្រាងច្បាប់សិទ្ធិទទួលព័ត៌មានមួយដែលបានផ្សព្វផ្សាយជាផ្លូវការកាលពីថ្ងៃទី២០ ខែ មេសា ឆ្នាំ ២០២០ ដោយក្រសួងព័ត៌មានបានបញ្ចប់ការពិគ្រោះពិភាក្សាជាមួយបណ្តាក្រសួងពាក់ព័ន្ធសំខាន់ៗ។ បន្ថែមពីពីនេះ ក្រុមការងារអង្គការសង្គមស៊ីវិលសម្តែងការគាំទ្រចំពោះប្រសាសន៍របស់ **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០២០ ក្នុងជំនួបជាមួយអ្នកសារព័ត៌មាន ដែលសម្តេចនឹងជម្រុញឲ្យមានច្បាប់សិទ្ធិទទួលព័ត៌មានក្នុងឆ្នាំ ២០២០នេះ។

លោក ឡាំ សុជាតិ នាយកវិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ យល់ឃើញថា "ច្បាប់សិទ្ធិទទួលព័ត៌មាន គឺផ្តល់ប្រយោជន៍ដល់រដ្ឋ វិស័យឯកជន ជាពិសេសប្រជាពលរដ្ឋ ព្រោះប្រជាពលរដ្ឋជាអ្នកប្រើប្រាស់សិទ្ធិ និងសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនិងសេរីភាពក្នុងការបញ្ចេញមតិ គឺអាស្រ័យលើសិទ្ធិទទួលព័ត៌មានជាចម្បង ជាពិសេសយុវជនក្លាយជាយុវជន

# សេចក្តីប្រកាសព័ត៌មាន

ដែលសកម្ម និងឈឺឆ្អាលបញ្ហាសង្គម សេដ្ឋកិច្ច គឺទាំងបច្ចុប្បន្ន និងអានាគត គឺច្បាប់នេះធានាសិទ្ធិ ប្រើប្រាស់ ក្នុងការទទួលព័ត៌មាន។

ឯកឧត្តម មាស សុភ័ណ្ឌ អនុរដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងព័ត៌មាន បានលើកឡើងថា "ក្រសួងនឹងពន្លឿន សេចក្តីព្រៀងច្បាប់សិទ្ធិទទួលព័ត៌មានឲ្យបានឆាប់ស្របតាមប្រសាសន៍ប្រមុខរដ្ឋាភិបាល។ ក្នុងនោះក្រសួងព័ត៌មាន បានបញ្ចប់ការឆ្លងយោបល់ និងពីគ្រោះជាមួយភាគីពាក់ព័ន្ធ  និងក្រសួងសំខាន់រួចរាល់ ហើយនឹងបញ្ជូនសេក្តីព្រាងច្បាប់នេះនៅទីស្តីការគណៈរដមន្ត្រីនាពេលដ៏ខ្លីខាងមុខនេះ។

សិក្ខាសាលាជជែកពិភាក្សាស្តីពីបច្ចុប្បន្នភាពនៃសេចក្តីព្រៀងច្បាប់សិទ្ធិទទូលព័ត៌មាន នាថ្ងៃ អង្គារ ទី ៣០ ខែមិថុនា ឆ្នាំ ២០២០ មានសារៈសំខាន់ណាស់ ក្នុងការរួមចំណែកធ្វើឱ្យប្រសើរឡើងនូវខ្លឹមសារនៃច្បាប់អោយមានស្តង់ដារអន្តរជាតិនិងការយល់ដឹងអំពីស្ថានភាពនៃសេចក្តីព្រាងច្បាប់សិទ្ធិទទូលព័ត៌មាន និងជំរុញឲ្យមានការអនុម័តច្បាប់ក្នុងឆ្នាំ២០២០នេះ។

**ទំនាក់ទំនង៖**


លោក ឡាំ សុជាតិ នាយកវិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ

តំណាងក្រុមការងារសិទ្ធិទទូលព័ត៌មាននៃអង្គការសង្គមស៊ីវិល

ទូរសព្ទ័ ៖ ០២៣ ២១៣ ៨៨៦ / ០១២ ៧១៨ ៦១១

អ៊ីម៉ែល ៖ socheat.lam@apiinstitute.org